www.kidworship.kr

# ការបង្កើតពិភពលោកនិងមនុស្សលោក

- 1st Story -


4Page

**Nar** កាលដើមដំបូងឡើយ ផែនដីមានពេញដោយភាពងងឹត ហើយនៅទទេ។
គឺគ្មានអ្វីទាល់តែសោះ។
គឺមានតែព្រះជាម្ចាស់ តែមួយប៉ុណ្ណោះ ដែលគង់នៅទីនោះ។
ថ្ងៃមួយ ព្រះជាម្ចាស់បាននិយាយថា

**God** ចូរអោយមានពន្លឺឡើង!

**Nar** នោះពន្លឺក៏មានឡើងចែងចាំងមកបំភ្លឺផែនដី។
ព្រះជាម្ចាស់បានមើលឃើញពន្លឺនោះថា ល្អហើយ។
ដូច្នេះ ព្រះជាម្ចាស់បានហៅ ពន្លឺនោះថាជា «ពេលថ្ងៃ»
និង ងងឹតនោះថាជា «ពេលយប់»។
ពេលនោះ ថ្ងៃទីមួយក៏បានចាប់ផ្តើមឡើង។


5Page

**Nar** ថ្ងៃទីពីរ ព្រះជាម្ចាស់បាននិយាយម្តងទៀតថា

**God** ចូរឲ្យមានផ្ទៃមេឃនិងទឹកកើតមក!

**Nar** ពេលនោះ ផ្ទៃមេឃនិងទឹកដ៏ស្រស់ស្អាត ក៏បានកើតមក។


6Page

**Nar** ថ្ងៃទីបី ព្រះជាម្ចាស់បានប្រមូលទឹកទាំងអស់ដាក់នៅក្នុងកន្លែងមួយ
ហើយព្រះអង្គក៏បានធ្វើអោយមានដីដុះឡើងមក។
បន្ទាប់មក ព្រះជាម្ចាស់បានអោយដីនោះ ដុះជាដើមផ្កាមានក្លិនក្រអូប
រីកស្រស់បំព្រងនិងមានដើមឈើពណ៌បៃតងដុះជាច្រើនចេញមក។
ព្រះជាម្ចាស់បានមើលឃើញទាំងនោះថា «ល្អហើយ»។


7Page

**Nar** ថ្ងៃទីបួន ព្រះជាម្ចាស់បាននិយាយថា

**God** ចូរឲ្យព្រះអាទិត្យ ព្រះច័ន្ទនិងផ្កាយជាច្រើនរះឡើងនៅលើផ្ទៃមេឃ!

**Nar** នៅពេលថ្ងៃ មានព្រះអាទិត្យបានរះឡើងនិងមានពន្លឺភ្លឺចែងចាំង
នៅលើផែនដី។ ហើយនៅពេលយប់ មានព្រះច័ន្ទនិងផ្កាយជាច្រើនបានរះ
ឡើងចែងចាំងបំភ្លឺនៅលើមេឃ។
ព្រះជាម្ចាស់បានមើលឃើញទាំងនោះថា «ល្អហើយ»។


8Page

**Nar** ថ្ងៃទីប្រាំ ព្រះជាម្ចាស់បាននិយាយថា

**God** ចូរឲ្យមានសត្វស្លាបហោះហើរពាសពេញលើផ្ទៃមេឃ
និងចូរអោយមានសត្វគ្រុបប្រភេទដែលរស់នៅក្នុងទឹកកើតឡើង។

**Nar** ពេលនោះ  ក៏មានសត្វស្លាបជាច្រើនបានហោះហើរពាសពេញលើផ្ទៃមេឃ។
ឯស្ទឹងទន្លេនិងសមុទ្រទាំងឡាយ  ក៏មានពេញដោយត្រី និងសត្វរស់នៅក្នុងទឹកជាច្រើនផ្សេងទៀត។
ថ្ងៃទីប្រាំមួយ    ព្រះជាម្ចាស់បានបង្កើតសត្វជើង៤ជាច្រើនប្រភេទនៅលើដី។

**God** ចូរឲ្យដីបង្កើតសត្វជើង៤ជាច្រើនប្រភេទឡើង!

**Nar** ពេលនោះ   ក៏មានសត្វមានជីវិតគ្រប់ប្រភេទបានកើតចេញមក។
មានចាប់តាំងពីដំរីដ៏ធំរឹងមាំទៅដល់
សត្វទន្សាយដ៏តូចៗនិងគួរឲ្យស្រលាញ់  មានខ្លាដ៏ក្លាហាន
និងសត្វជាច្រើនប្រភេទទៀត ដែលបានសរសើរដំកើង ដល់ព្រះជាម្ចាស់។
ពេលនោះ ព្រះជាម្ចាស់បានសប្បាយចិត្តយ៉ាងខ្លាំង។

---



9Page

**Nar** ជាចុងក្រោយ  ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់។
ព្រះជាម្ចាស់បានសូនមនុស្សពីធូលីដីមក ហើយព្រះអង្គក៏បញ្ចូលខ្យល់ដង្ហើមតាមរន្ធច្រមុះឲ្យមនុស្សនោះមានជីវិតរស់ឡើង។
នេះជាមនុស្សទី១ ដែលព្រះជាម្ចាស់បានបង្កើតមកឈ្មោះថា  «អាដាម»។
ព្រះជាម្ចាស់បាននិយាយទៅអាដាមថា

**God** ចូរបង្កើតកូនចៅឲ្យបានជាច្រើនឡើងពាសពេញលើផែនដី
ហើយគ្រប់គ្រងលើសត្វមានជីវិតទាំងអស់  ដែលកំពុងរស់នៅលើដីចុះ។

**Nar** នៅថ្ងៃទីប្រាំពីរ   ព្រះជាម្ចាស់បានបញ្ចប់ការងាររបស់ទ្រង់ហើយ។
ពេលនោះ ព្រះអង្គក៏បានឈប់សំរាក។
ព្រះជាម្ចាស់បានឲ្យពរដល់ថ្ងៃទីប្រាំពីរ
និងបានញែកទុកថ្ងៃនោះអោយបានបរិសុទ្ធ។
ហេតុនេះ យើងជាកូនរបស់ព្រះជាម្ចាស់  ក៏ត្រូវឈប់សំរាកនៅថ្ងៃទីប្រាំពីរ
និងទុកថ្ងៃនោះជាថ្ងៃបរិសុទ្ធសម្រាប់ព្រះជាម្ចាស់ដែរ។